# អនិច្ចំ

ខ្ញុំឈរមាត់ទឹកនឹកសង្វេគ ស្តាយ**ធីតាឯក**កេរដីដូន
ខ្ញុំធ្លាប់រត់លេងជុំបងប្អូន ឥឡូវបាត់សូន្យសល់ជលធា។
ខ្ញុំឈរមាត់ច្រាំងភាំងភ្លាំងភ្លឹក មើលទឹកនឹកឃើញដល់គ្រឹហា

ផ្ទះឈើឈរខ្ពស់ហួសពសុធា មានទ្វារមុខក្រោយជណ្តើរពីរ។
មុខផ្ទះមានសួនល្អប៉ប្រិម យាយគាត់ដាំខ្ទឹមស្លឹកគ្រៃជីរ
មានងប់ត្រប់ម្ទេសម្រះព្រៅផ្ទីរ ចុះពីលើផ្ទះបេះបានស្ល។
មានទាំងបុប្ផជាតិផងស្នេកស្ពៈ យាយដាំថ្វាយព្រះនិងលម្អ
សិរមាន់ស្បៃរឿងម្លិះបវរ យាយបេះសុំពរឧបោសថ។
ជុំវិញភូមិដ្ឋានមានឈើផ្លែ ដូងចេកខ្នុរហែផ្លែមិនហត់
ក្រូចថ្លុងសេដាមៀនទៀបល្មុត ស្វាយខ្ទិះឈ្មុយផុតឆ្ងាញ់លើសគេ។
ហួសចម្ការស្វាយក្រោយគេហា មុននឹងយាត្រាដល់ទន្លេ
មានវាលខ្សាច់ល្បាប់ចំណាប់ទ្វេ យាយមិនទំនេរខំដាំដុះ។
បន្លែរុក្ខជាតិតាមរដូវ ពោតត្រសក់ស្រូវន្លូវប៉េងប៉ោះ
ល្ពៅសណ្តែកដីឆីមិនអស់ ដំឡូងជ្វាចុះមើមច្រើនក្តាត់។
អកុសលផលកម្មនៃធម្មជាតិ ឱ្យចិត្តចង្អៀតពិបាកកាត់
ជីដូនជរាលាលោកបាត់ តាមកាលកំណាត់សត្តក្ខ័យ។
អនិច្ចាដីកេរក៏មិននៅ បានបាត់បង់ទៅក្នុងជលស័យ
ចរន្តទឹកជន់គ្មានប្រណី បុកបាក់ច្រាំងដីមាត់ទន្លេ។
ជាងដប់ឆ្នាំសោះអស់គ្មានសល់ ដូចកល់សុបិនមិនគួរទេ
ពេលញាតិស្តីប្រាប់ស្តាប់ហើយគ្នេរ រភ្នែកមើលទឹកនឹកអួលផ្សា។
ដីកេរខ្ញុំធ្លាប់ស្នាក់អាស្រ័យ ពេលមកលេងយាយផ្ទះចម្ការ
ឥឡូវសល់ត្រឹមផ្ទៃជលសា បីរយម៉ែត្រណាអំពីច្រាំង។
ដង្ហើមធំដកស្រក់ទឹកភ្នែក វិវេកនឹកដល់អនិច្ចំ
មានកើតមានស្លាប់រាល់រូបំ ជីវិតតាំងនៅវេលាខ្លី។
មិនថារុក្ខជាតិសត្វឬមនុស្ស កើតរស់រួចស្លាប់ទៅវិញខ្ចី
ច្នេះមនុស្សគួររស់ដោយគប្បី ទុកកេរ្តិ៍ប្រពៃឱ្យកូនចៅ។

ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី